

សេចក្តីសង្ខេបនៃរបកគំហើញ

# ការអនុវត្តក្របខណ្ឌច្បាប់ចំពោះអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា

## ករណីសិក្សានៅកម្ពុជា

Rebecca Nhep និង Dr Kate van Doore

Griffith UNIVERSITY Queensland, Australia Law Futures Centre
UBS Optimus Foundation | UBS
Better Care Network

## សារតា

អំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា គឺជាប្រភេទនៃអំពើជួញដូរកុមារដែលពាក់ព័ន្ធនឹងការជ្រើសរើស និង/ឬការផ្ទេរកុមារទៅកាន់កន្លែងថែទាំកុមារ (RCFs) ឬ "មណ្ឌលកុមារកំព្រា" សម្រាប់គោលដៅនៃការកេងប្រវ័ញ្ច ការស្វែងរកប្រយោជន៍ ឬស្មុំកូន។[1] ជាទូទៅ អំពើជួញដូរបែបនេះកើតឡើងនៅបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម ដែលប្រព័ន្ធកិច្ចការពារកុមារមានលក្ខណៈឯកជនីយកម្មកម្រិតខ្ពស់ មានការគ្រប់គ្រងមិនគ្រប់គ្រាន់ និងពឹងផ្អែកជាចម្បងទៅលើមូលនិធិពីបរទេស។

របាយការណ៍ ស្តីពីអំពើជួញដូរកុមារទៅក្នុងមណ្ឌលកុមារកំព្រានៅកម្ពុជា ក្នុងគោលដៅកេងប្រវ័ញ្ច មានចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០មក។ ករណីដំបូងៗនៃករណីទាំងនោះ មានទំនាក់ទំនងជាចម្បងជាមួយនឹងស្មុំកូនអន្តរប្រទេសបែបក្លែងបន្លំ។ នាពេលថ្មីៗនេះ អំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រាបានលេចឡើងនូវទម្រង់ថ្មីមួយបែបទៀត ដែលមានគោលដៅចម្បង ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ កេងប្រវ័ញ្ចពលកម្ម និង/ឬស្វែងរកប្រយោជន៍ ។

តាមរយៈការអនុម័តច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ច្បាប់ TSE) នៅឆ្នាំ២០០៨ បានចែងអំពីបទល្មើសថ្មីៗ ក៏ដូចជាបានចែងអំពីក្របខណ្ឌច្បាប់ដ៏ច្បាស់លាស់មួយ សម្រាប់ធ្វើការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រានៅកម្ពុជា។[2] ភាគច្រើននៃបទល្មើសជួញដូរកុមារដែលមានចែងនៅក្នុងច្បាប់ TSE ត្រូវបានកំណត់អំពីធាតុផ្សំនៃ "ការនាំយកកុមារចេញដោយមិនស្របច្បាប់" និង "គោលដៅ" ដែលរាប់បញ្ចូលទាំងទម្រង់ទូទៅនៃការកេងប្រវ័ញ្ច បន្ថែមទៅលើការស្វែងរកប្រយោជន៍ និងស្មុំកូនផងដែរ។ ការបញ្ចូលការស្វែងរកប្រយោជន៍ជាគោលដៅមួយ សម្រាប់ការនាំយកចេញដោយមិនស្របច្បាប់ សឱ្យឃើញពីការអភិវឌ្ឍដ៏ល្អ

1 Kathryn E Van Doore, 'Paper orphans: Exploring child trafficking for the purpose of orphanages' (2016) 24(2) *The International Journal of Children's Rights* 378-407.

2 ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ដែលប្រកាសប្រើឱ្យច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ, (២០០៨), ប្រទេស កម្ពុជា; R, Nhep., van Doore, K., *Legal Framework for Orphanage Trafficking Cambodia*, (2021), Griffith University.

ជាពិសេសមួយនៃច្បាប់នេះ ហើយវាបានត្រួសត្រាយផ្លូវ ដើម្បីធ្វើឱ្យទម្រង់ដែលគេបានស្គាល់ទាំងអស់ពាក់ព័ន្ធអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ក្លាយទៅជាបទល្មើសដែលអាចផ្តន្ទាទោសបាន រួមទាំងការនាំយកកុមារចេញដោយមិនស្របច្បាប់ពីគ្រួសារ និងការទុកដាក់ពួកគេនៅក្នុងមណ្ឌលកុមារកំព្រាក្នុងគោលដៅស្វែងរកប្រយោជន៍ផងដែរ។

បន្ថែមលើកំណែទម្រង់ច្បាប់ព្រហ្មទណ្ឌ កម្ពុជាបានបង្កើតឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រឹងប្រព័ន្ធកិច្ចការពារកុមារ និងការថែទាំជំនួស នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ កិច្ចខិតខំប្រឹងប្រែងនានារួមមានការធ្វើកំណែទម្រង់ច្បាប់ ការកាត់បន្ថយចំនួនមណ្ឌលថែទាំកុមារ ការរៀបចំក្របខណ្ឌច្បាប់សម្រាប់ការថែទាំកុមារដោយឪពុកម្តាយធម៌ និងសុំកូន ការពង្រឹងប្រព័ន្ធទប់ស្កាត់ការទុកដាក់កុមារនៅក្នុងការថែទាំជំនួស ការរៀបចំឌីជីថលនីយកម្មប្រព័ន្ធអធិការកិច្ច ការរៀបចំយន្តការ និងសេវាកិច្ចការពារកុមារនៅកម្រិតមូលដ្ឋាន ការពង្រឹងការទទួលបានសេវាកិច្ចគាំពារសង្គម និងការផ្តល់សេវាគ្រប់គ្រងករណីសម្រាប់សមាហរណកម្ម។[3] កិច្ចខិតខំប្រឹងប្រែងដ៏គួរឱ្យសរសើរទាំងនេះកំពុងដំណើរការឆ្ពោះទៅរកការកាត់បន្ថយភាពងាយរងគ្រោះរបស់ឪពុកម្តាយ និងកុមារដោយសារអំពើជួញដូរ និងកេងប្រវ័ញ្ចក្នុងទម្រង់ជាមណ្ឌលកុមារកំព្រា និងបង្ការកុំឱ្យមានប្រតិបត្តិការមណ្ឌលកុមារកំព្រាបែបអាជីវកម្ម។

ថ្វីបើមានការអភិវឌ្ឍជាវិជ្ជមានពាក់ព័ន្ធនឹងការពង្រឹងច្បាប់ និងប្រព័ន្ធកិច្ចការពារកុមារក្តី ការរាយការណ៍អំពីករណីនៃការកេងប្រវ័ញ្ច និងការសង្ស័យពាក់ព័ន្ធអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រានៅតែបន្តកើតមាន។ យ៉ាងណាមិញ ពុំមានករណីណាមួយត្រូវបានធ្វើការចោទប្រកាន់លើជនល្មើសពីបទល្មើសជួញដូរកុមារឡើយ។ របាយការណ៍នេះសិក្សាអំពីការប្រព្រឹត្តចំពោះករណីដែលត្រូវបានស៊ើបអង្កេតពាក់ព័ន្ធការកេងប្រវ័ញ្ចកុមារនៅក្នុងកន្លែងថែទាំកុមារដែលអាចនាំឱ្យមានការសង្ស័យយ៉ាងសមហេតុផលទៅលើអត្ថិភាពនៃអំពើជួញដូរណាមួយ ដែលមានចែងនៅក្នុងច្បាប់។ បន្ថែមពីនេះ របាយការណ៍នេះបង្ហាញអំពីភាពខ្វះចន្លោះនៃការអនុវត្តក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងកត្តានានាដែលរារាំងការអនុវត្តច្បាប់ប្រកបដោយសង្គតិភាព។

## អំពីការសិក្សាស្រាវជ្រាវ និងរបាយការណ៍សង្ខេប

ការសិក្សាស្រាវជ្រាវនេះត្រូវធ្វើឡើងជាផ្នែកមួយនៃគម្រោងស្រាវជ្រាវពហុប្រទេស ដែលមានច្រើនដំណាក់កាល ដែលត្រូវបានរចនាឡើង ដើម្បីពង្រឹងការកំណត់អត្តសញ្ញាណ ការផ្តន្ទាទោស និងការទប់ស្កាត់បទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ការសិក្សាស្រាវជ្រាវនេះគឺជាដំណាក់កាលទីពីរនៃដំណាក់កាលទាំងបួន ដែលត្រូវធ្វើនៅកម្ពុជា ក្នុងនាមជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនបី ដែលត្រូវបានជ្រើសរើសមកធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវនេះ។ ដំណាក់កាលទីពីរនៃគម្រោងនេះ គឺជាការស្រាវជ្រាវលើផ្នែកសង្គម និងផ្នែកច្បាប់ ដែលត្រូវបានរចនាឡើង ដើម្បីពិនិត្យមើលការអនុវត្តជាក់ស្តែងនូវក្របខណ្ឌច្បាប់សម្រាប់ការផ្តន្ទាទោសអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រានៅកម្ពុជា។ ជាពិសេស ការសិក្សាស្រាវជ្រាវមានគោលបំណងកំណត់អំពីរបៀប ដែលអាជ្ញាធរពាក់ព័ន្ធបកស្រាយ និងដោះស្រាយករណីនានាដោយផ្អែកតាមច្បាប់នៅពេលមានការបង្ហាញអំពីអត្ថិភាពនៃអំពើជួញដូរ និងការកេងប្រវ័ញ្ចក្នុងមណ្ឌលកុមារកំព្រា។ បន្ថែមពីនេះ ការសិក្សាស្រាវជ្រាវនេះបានព្យាយាមពិនិត្យមើលឥទ្ធិពលនៃកត្តាវប្បធម៌សង្គមទៅលើកិច្ចការពារកុមារ ការអនុវត្តច្បាប់ និងការបកស្រាយច្បាប់ ព្រមទាំងសេចក្តីសម្រេចរបស់តុលាការ និងកំណត់នូវបញ្ហាប្រឈមនានាចំពោះការអនុវត្តច្បាប់ប្រកបដោយសង្គតិភាពចំពោះករណីជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ របាយការណ៍មួយនេះ គឺជាការបង្ហាញអំពីសេចក្តីសង្ខេបនៃលទ្ធផលស្រាវជ្រាវដែលបានមកពីទិន្ន័យសំណុំរឿង និងការវិភាគសំណុំរឿង នៅក្នុងការសិក្សាស្រាវជ្រាវដំណាក់កាលទីពីរនេះ។

# របកគំហើញសំខាន់ៗ

## របកគំហើញ ផ្នែក ក៖ ការវិភាគលើករណីនៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រាដែលត្រូវបានស៊ើបអង្កេត

ករណីជាក់លាក់ចំនួន ៧២ករណី ទាក់ទងនឹងអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និង/ឬការកេងប្រវ័ញ្ចលើកុមារនៅក្នុងកន្លែងថែទាំកុមារ ត្រូវបានលើកមកបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវនេះ។ ករណីជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និង/ឬការកេងប្រវ័ញ្ចលើកុមារ ដែលត្រូវបានរកឃើញ មានការជាប់ពាក់ព័ន្ធទៅនឹងកន្លែងថែទាំកុមារចំនួន ៦៩កន្លែង។ ករណីដែលមានជនសង្ស័យ និងជនល្មើសទោល បានកើតឡើងនៅក្នុងកន្លែងថែទាំកុមារចំនួន ៩៦% ហើយករណីដែលមានជនល្មើសចំនួន ២នាក់ ឬច្រើនជាងនេះ ត្រូវបានរកឃើញ និងស៊ើបអង្កេតនៅក្នុងកន្លែងថែទាំកុមារចំនួន ២។ ក្នុងចំណោមករណីទាំងអស់ មានជនរងគ្រោះយ៉ាងតិចបំផុតចំនួន ៤៤០នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណ។

### ទិន្នន័យសង្ខេបអំពីសំណុំរឿង៖

- ក្នុងចំណោមករណីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ដែលត្រូវបានសង្ស័យ ៦៧% បានកើតឡើងនៅក្នុងកន្លែងថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ១៥% នៅក្នុងកន្លែងថែទាំកុមារបែបជំនឿសាសនា ១២% នៅក្នុងកន្លែងថែទាំកុមាររបស់បុគ្គលឯកជន និង ៦% នៅក្នុងកន្លែងថែទាំកុមាររបស់រដ្ឋ។
- ក្នុងចំណោមជនសង្ស័យ/ជនល្មើស ៣១% គឺជាប្រធានកន្លែងថែទាំកុមារ ២៨% គឺជាស្ថាបនិក ១៦% គឺជាអ្នកស្ម័គ្រចិត្តបរទេស ១១% គឺជាមេដឹកនាំសាសនា និង ១០% គឺជាបុគ្គលិក សាច់ញាតិ ឬម្ចាស់ជំនួយ។
- ក្នុងចំណោមករណីទាំងនេះ ៣៨% បានកើតឡើងនៅក្នុងកន្លែងថែទាំកុមារ ដែលមិនបានចុះបញ្ជី ៨% នៅក្នុងកន្លែងថែទាំកុមារដែលបានចុះបញ្ជី និង ៥៤% នៃករណីទាំងនេះបានកើតឡើងនៅក្នុងកន្លែងថែទាំកុមារ ដែលគេមិនបានដឹងអំពីស្ថានភាពនៃការចុះបញ្ជី។

ស្ទើរតែគ្រប់ពេល មានតែករណីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទប៉ុណ្ណោះ ដែលត្រូវបានចោទប្រកាន់។ នៅក្នុងករណីទាំងនេះ ជនល្មើសបានទទួលរងការចោទប្រកាន់ជាចម្បងពីបទល្មើសការបំពានខាងផ្លូវភេទ ហើយគ្មានករណី ដែលជនល្មើសបានទទួលរងការចោទប្រកាន់ពីការនាំយកចេញដោយមិនស្របច្បាប់ ឬការផ្ទេរ ឬការទទួលកុមារ ដែលត្រូវបាននាំយកចេញដោយមិនស្របច្បាប់ សម្រាប់គោលដៅកេងប្រវ័ញ្ច ស្វែងរកប្រយោជន៍ ឬសុំកូន (ការចោទប្រកាន់ពីបទល្មើសជួញដូរកុមារ) ឡើយ។ កម្រមានការស៊ើបអង្កេតត្រូវបានធ្វើឡើងក្នុងករណីដែលការស្វែងរកប្រយោជន៍ និងសុំកូន គឺជាគោលដៅចម្បងដែលត្រូវបានលើកឡើង ហើយគ្មានការបង្ហាញអំពីការកេងប្រវ័ញ្ចផ្លូវភេទណាស់។ គ្មានកំណត់ត្រាអំពីករណីបែបនេះ ដែលត្រូវបានបន្តនីតិវិធីទៅដល់ដំណាក់កាលជំនុំជម្រះឡើយ។ ករណីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ដែលពាក់ព័ន្ធនឹងការស្វែងរកប្រយោជន៍ និងសុំកូនភាគច្រើនគ្មានការរាយការណ៍ឡើយ និងទំនងជាមានវឌ្ឍនភាពតិចតួចណាស់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។



# របកគំហើញផ្នែក ខ៖ ឧបសគ្គផ្នែកវប្បធម៌សង្គមចំពោះការស្វែងរក និងការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា

## ទិន្នន័យសង្ខេបអំពីរបកគំហើញសំខាន់ៗ៖

ឧបសគ្គចម្បងចំពោះការអនុវត្តក្របខណ្ឌច្បាប់ប្រកបដោយសង្គតិភាព ក្នុងការស្វែងរក ការផ្តន្ទាទោស និងការទប់ស្កាត់បទល្មើសជួញដូរក្នុងទម្រង់ជាមណ្ឌលកុមារកំព្រា ដែលត្រូវបានរកឃើញតាមរយៈការសិក្សាស្រាវជ្រាវនេះ រួមមាន៖

- កង្វះការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ ដែលមានចរិតលក្ខណៈដើម្បីទប់ស្កាត់បទល្មើស រួមមានការដាក់ទណ្ឌកម្មលើប្រតិបត្តិការកន្លែងថែទាំកុមារដោយមិនស្របច្បាប់ និងបទល្មើសពាក់ព័ន្ធនឹងការនាំយកកុមារចេញដោយមិនស្របច្បាប់ និងការញុះញង់ឱ្យមានការបោះបង់កុមារ។ នេះគឺជាឧបសគ្គចំពោះការទប់ស្កាត់ និងបានរួមចំណែកធ្វើឱ្យធាតុផ្សំនៃបទល្មើសជួញដូរកុមារនៅក្នុងមណ្ឌលកុមារកំព្រាក្លាយទៅជារឿងធម្មតា។
- កង្វះការចែងពីបទល្មើសដោយឡែកពាក់ព័ន្ធការលួងលោមនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ កង្វះខាតបែបនេះបានបង្កជាឧបសគ្គដល់សមត្ថភាពរបស់ភាគីពាក់ព័ន្ធ រួមមានអាជ្ញាធរដែលមានសមត្ថកិច្ច ក្នុងការស្រាវជ្រាវរកបទល្មើស និងបង្ហាញអំពីភាពខុសគ្នារវាងការប្រព្រឹត្តដែលជា “ការថែទាំ” និងចេតនាក្នុងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ វាបានកាត់បន្ថយលទ្ធភាពនៃការធ្វើអន្តរាគមន៍នៅមុនពេលការរំលោភបំពានផ្លូវភេទកើតមានឡើង។ វាក៏បានកាត់បន្ថយកិច្ចការពារសម្រាប់អនីតិជន ដែលមានវ័យលើសនីតិភាពនៃការរួមភេទ ដែលត្រូវបានជួញដូរសម្រាប់គោលដៅកេងប្រវ័ញ្ចផ្លូវភេទផងដែរ។
- កង្វះការស៊ើបអង្កេតជាប្រចាំទៅលើនីត្យានុកូលភាពនៃការនាំយកចេញ និងការទទួលកុមារចូលក្នុងកន្លែងថែទាំកុមារ ជាពិសេស នៅក្នុងបរិបទនៃការស៊ើបអង្កេតទៅលើការប្រវ័ញ្ចកុមារនៅក្នុងកន្លែងថែទាំកុមារ។ នេះមានន័យថា វិសាលភាពនៃអំពើល្មើសកម្រត្រូវបានស្រាវជ្រាវពេញលេញណាស់ ហើយធាតុផ្សំនៃការនាំយកចេញដោយមិនស្របច្បាប់ ក៏កម្រត្រូវបានបង្ហាញនៅក្នុងកំណត់ហេតុលើការស្រាវជ្រាវដែរ។ កង្វះការស៊ើបអង្កេតជាប្រចាំនេះ បង្កឱ្យមានផលប៉ះពាល់ទៅលើការចោទប្រកាន់ ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការកំណត់អត្តសញ្ញាណជនល្មើស ជាពិសេសបុគ្គលទាំងឡាយដែលបានចូលរួមនៅក្នុងដំណើរការនៃការនាំយកកុមារចេញ ការផ្ទេរ និងការទទួលកុមារ។
- ការអនុវត្តការស៊ើបអង្កេតបែបប្រតិកម្មក្រោយពេលបញ្ហាកើតឡើង និងភាពស្ទាក់ស្ទើរនៅក្នុងចំណោមនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតធាតុផ្សំ ឬរកអង្គហេតុដែលកើតឡើងជាយូរមកហើយ ដូចបានរៀបរាប់ខាងលើដែរ ការធ្វើបែបនេះបានកម្រិតដល់ការស្រាវជ្រាវរកធាតុផ្សំនៃបទល្មើសការនាំយកចេញដោយមិនស្របច្បាប់ និងបានបង្កឱ្យមានវិសាលភាពចង្អៀតក្នុងការស៊ើបអង្កេត និងនាំឱ្យមានការសម្រេចផ្តន្ទាទោសលើការកេងប្រវ័ញ្ចដែលជាបទល្មើសគួរឱ្យកត់សម្គាល់ជាជាងបទល្មើសជួញដូរកុមារ។
- ការយល់ដឹងនៅមានកម្រិត និង/ឬការយល់ដឹងមិនមានសង្គតិភាពគ្នាអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងសូចនាករនៃអំពើនេះ ជាពិសេសនៅក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរកិច្ចការពារកុមារថ្នាក់ក្រោមជាតិ។ បញ្ហានេះបានបង្កជាឧបសគ្គដល់ការពិនិត្យអត្ថិភាពនៃបទល្មើស ការរាយការណ៍ និងកម្រិតនូវវិសាលភាពនៃការស៊ើបអង្កេត។
- ការលំបាកក្នុងការប្រមូលភស្តុតាងគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យបើកការស៊ើបអង្កេត។ បញ្ហានេះកើតឡើងដោយសារឧបសគ្គផ្នែកដែនសមត្ថកិច្ច ដែលបានដាក់កម្រិតចំពោះការចូលទៅកាន់កន្លែងថែទាំកុមារ និងកង្វះបទប្បញ្ញត្តិច្បាប់ដែលចែងអំពីការស៊ើបអង្កេតដោយភ្នាក់ងារសម្ងាត់។

- បញ្ហាដែនសមត្ថកិច្ច និងលទ្ធភាពចូលទៅកាន់កន្លែងថែទាំ ដែលកើតចេញពីការចុះបញ្ជីកន្លែងថែទាំកុមារនៅក្រោមក្រសួងនានា។ លក្ខខណ្ឌក្នុងការទទួលបានការអនុញ្ញាតពីក្រសួងពាក់ព័ន្ធដែលមានសមត្ថកិច្ចចុះបញ្ជី ក្នុងពេលអនុវត្តជាក់ស្តែង នៅមុនពេលចូលទៅកាន់កន្លែងថែទាំកុមារ បានបង្កឱ្យមានផលប៉ះពាល់ទៅលើការធ្វើអធិការកិច្ចកន្លែងថែទាំកុមារមួយចំនួន ជាពិសេស កន្លែងថែទាំកុមារបែបសាសនា និងបានបង្កឱ្យមានភាពយឺតយ៉ាវក្នុងការប្រមូលភស្តុតាង និងធ្វើអន្តរាគមន៍ ដើម្បីឆ្លើយតបនឹងបញ្ហាដែលបានរាយការណ៍។
- អសង្គតិភាពក្នុងការអនុវត្តប្រព័ន្ធអធិការកិច្ច និងពិនិត្យតាមដានកន្លែងថែទាំកុមារ។ ការធ្វើអធិការកិច្ចមិនរមែងតែងត្រូវបានធ្វើឡើងឱ្យបានគ្រប់ជ្រុងជ្រោយ ស៊ីជម្រៅ ឬជាទៀងទាត់ឡើយ។ បញ្ហានេះបានបង្កលក្ខណៈងាយស្រួលដល់កន្លែងថែទាំកុមារក្នុងការបិទបាំងការមិនអនុវត្តទៅតាមបទដ្ឋានអប្បបរមា លាក់បាំងភាពមិនប្រក្រតីនៅក្នុងការអនុវត្ត និងគេចវេសវិធានការកែតម្រូវចំពោះការប្រព្រឹត្តមិនស្របច្បាប់របស់ពួកគេ។ បញ្ហានេះធ្វើឱ្យការពិនិត្យអត្តិភាពនៃបទល្មើស និងការរាយការណ៍នៅមានកម្រិត ដែលបានបង្កលក្ខណៈងាយស្រួលដល់កន្លែងថែទាំកុមារដែលប្រព្រឹត្តអំពើកេងប្រវ័ញ្ចក្នុងការបន្តប្រតិបត្តិការរបស់ខ្លួនដោយគ្មានការធ្វើអន្តរាគមន៍។
- ការធ្វើឱ្យធាតុផ្សំនៃបទល្មើសជួញដូរក្នុងទម្រង់ជាមណ្ឌលកុមារកំព្រាក្លាយទៅជារឿងធម្មតា រួមមានអំពើបង្កឱ្យមានការចូលរួមរបស់កុមារនៅក្នុងសកម្មភាពស្វែងរកមូលនិធិនៅក្នុងមណ្ឌលកុមារកំព្រា ការទទួលយកកុមារចូលក្នុងកន្លែងថែទាំកុមារដោយមិនប្រក្រតី និងប្រតិបត្តិការកន្លែងថែទាំកុមារដោយលួចលាក់។ បញ្ហានេះបានធ្វើឱ្យភាគីពាក់ព័ន្ធនានាលែងសូវយកចិត្តទុកដាក់ចំពោះសូចនាករនៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ជាពិសេស ធាតុផ្សំនៃការនាំយកចេញដោយមិនស្របច្បាប់ និងដោយមានគោលដៅស្វែងរកប្រយោជន៍ ហើយបញ្ហានេះបានដាក់កម្រិតចំពោះលទ្ធភាពនៃការពិនិត្យអត្តិភាពនៃបទល្មើស ការរាយការណ៍ និងការបញ្ជូនសំណុំរឿង។
- ឧបសគ្គចំពោះជនរងគ្រោះក្នុងការរាយការណ៍ និងចូលរួមក្នុងដំណើរការតុលាការ។ ឧបសគ្គទាំងនេះរួមមាន ការទទួលរងការមាក់ងាយ វប្បធម៌នៃការមានផ្នត់គំនិតដឹងគុណ និងមានកាតព្វកិច្ចចំពោះជនល្មើសដែលបានដើរតួជាអ្នកជួយឧបត្ថម្ភកុមារ ដំណើរការនីតិវិធីជំនុំជម្រះដែលមានរយៈពេលវែង កង្វល់ពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្តសារឡើងវិញ កង្វះជំនឿលើប្រព័ន្ធតុលាការក្នុងចំណោមគ្រួសារមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប និងការកៀបសង្កត់លើជនរងគ្រោះ និងការជ្រៀតជ្រែកពីសំណាក់ជនល្មើស។
- ទំនាក់ទំនងរវាងអ្នកឧបត្ថម្ភ និងអតិថិជន (patron-client) ដែលត្រូវបានបង្កើតឡើងរវាងប្រតិបត្តិករមណ្ឌលកុមារកំព្រា និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុង និងក្រៅមណ្ឌលកុមារកំព្រា។ ទំនាក់ទំនងទាំងនេះបានរារាំងដល់ការរាយការណ៍ និងការបង្ហាញឱ្យដឹងពីបទល្មើស ដែលនាំឱ្យមានការកាត់បន្ថយនូវការទទួលពត៌មានអំពីការរំលោភបំពាន និងបង្កឱ្យមានការជ្រៀតជ្រែកក្នុងការស៊ើបអង្កេត ឬការអនុវត្តវិធានការកែតម្រូវដោយអាជ្ញាធរកិច្ចការពារកុមារ។

ការសិក្សាស្រាវជ្រាវនេះបានកំណត់នូវភាពខ្វះចន្លោះក្នុងការអនុវត្តក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត និងកត្តាមួយចំនួនដែលបង្កជាឧបសគ្គចំពោះការអនុវត្តច្បាប់ប្រកបដោយសង្គតិភាព។ ឧបសគ្គទាំងនេះរួមមាន ឧបសគ្គដែលស្ថិតនៅកម្រិតផ្សេងៗគ្នានៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រព័ន្ធកិច្ចការពារកុមារ និងប្រតិបត្តិការផ្ទៃក្នុងនៃកន្លែងថែទាំកុមារ។ឧបសគ្គបន្ថែមទៀតបានកើតចេញពីការយល់ដឹងនៅមានកម្រិតអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា ទស្សនៈរបស់សហគមន៍ចំពោះការថែទាំកុមារក្នុងមណ្ឌលកុមារកំព្រា ផ្នត់គំនិត និងនិយាមផ្នែកវប្បធម៌ពាក់ព័ន្ធនឹងការដឹងគុណ និងការមានកាតព្វកិច្ចរវាងអ្នកឧបត្ថម្ភ និងអតិថិជន។

ឧបសគ្គនានាពាក់ព័ន្ធនឹងចំណេះដឹង និងការយល់ដឹងរួមមាន កម្រិតនៃការយល់ដឹងខុសៗគ្នាអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងសូចនាករនៃអំពើជួញដូរបែបនេះ ព្រមទាំងចំណេះដឹងបច្ចេកទេសពាក់ព័ន្ធនឹងបទល្មើស

ជួញដូរកុមារនៅក្នុងច្បាប់ TSE ក្នុងចំណោមភាគីពាក់ព័ន្ធ។ ចំណេះដឹងកម្រិតខ្ពស់បំផុតមាននៅក្នុងចំណោមអង្គចៅក្រម មន្ត្រីតុលាការ និងអង្គការស៊ើបអង្កេតជំនាញ។ ចំណេះដឹងកម្រិតទាបបំផុតមាននៅក្នុងចំណោមអាជ្ញាធរមូលដ្ឋាន អាជ្ញាធរកិច្ចការពារកុមារថ្នាក់ក្រោមជាតិ និងនគរបាលយុត្តិធម៌ ដែលជាមន្ត្រីជួរមុខពាក់ព័ន្ធនឹងការពិនិត្យអត្តិភាពនៃបទល្មើស ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការកសាងសំណុំរឿង។ គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប គឺជាយន្តការយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងការពិនិត្យអត្តិភាពនៃបទល្មើស និងកំណត់អត្តសញ្ញាណជនរងគ្រោះ ជាពិសេសនៅក្នុងចំណោមមន្ត្រីជួរមុខ។ ទោះបីជាយ៉ាងណាក្តី គោលការណ៍ណែនាំនេះមិនបានរួមបញ្ចូលនូវសូចនាករភាគច្រើននៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រាឡើយ។ ហេតុនេះហើយ គ្មានក្របខណ្ឌច្បាប់ច្បាស់លាស់ដើម្បីផ្តល់ជាមគ្គុទ្ទេសក៍ចំពោះការពិនិត្យអត្តិភាពនៃបទល្មើសដល់មន្ត្រីជួរមុខ ដែលរមែងតែងខ្វះការបណ្តុះបណ្តាលឯកទេសក្នុងការបកស្រាយច្បាប់ ដែលមន្ត្រីថ្នាក់លើនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទទួលបានការបណ្តុះបណ្តាលឡើយ។ បញ្ហានេះបង្កជាឧបសគ្គចំពោះការស្រាវជ្រាវរកបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងលទ្ធភាពនៃការធ្វើចំណាត់ការ និងការមានវឌ្ឍនភាពលើសំណុំរឿងនានានៅក្នុងដំណើរការស៊ើបអង្កេតទាំងមូល។

ការពិនិត្យអត្តិភាពនៃបទល្មើស និងការបកស្រាយច្បាប់មានភាពស្មុគស្មាញបន្ថែមទៀតដោយសារបទល្មើសទាំងនេះបានកើតឡើងនៅក្នុងមណ្ឌលកុមារកំព្រា ខណៈពេលដែលមណ្ឌលកុមារកំព្រានៅមានវត្តមានយ៉ាងទូលំទូលាយ ហើយសង្គមភាគច្រើនយល់ឃើញថា មណ្ឌលកុមារកំព្រាជាកន្លែងផ្តល់សេវាកិច្ចការពារកុមារដ៏ចាំបាច់។ បញ្ហានេះបានកាត់បន្ថយការត្រួតពិនិត្យទៅលើកន្លែងថែទាំកុមារ និងប្រតិបត្តិការរបស់ពួកគេ និងបានបង្កឱ្យមានភាពស្មុគស្មាញក្នុងការស្វែងយល់អំពីធាតុផ្សំ ឬសូចនាករផ្សេងៗនៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា រួមមានការលួងលោម និងការចាត់ទុកកុមារដូចជាទំនិញ។ វាបានធ្វើឱ្យអាជ្ញាធរមានការលំបាកក្នុងការបង្ហាញអំពីភាពខុសគ្នារវាង “ការថែទាំ” និងការកេងប្រវ័ញ្ចនៅក្នុងដំណើរការស្វែងរកភស្តុតាងនៃបទល្មើស។ មួយវិញទៀត ការស៊ើបអង្កេតក្នុងវិសាលភាពតូចចង្អៀត និងកង្វះការស៊ើបអង្កេតលក្ខណៈបុរេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការស៊ើបអង្កេត ក៏បានធ្វើឱ្យការពិនិត្យអត្តិភាពនៃបទល្មើស និងការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រាមានកម្រិតផងដែរ។ ការស៊ើបអង្កេតនានាទំនងជានៅមានកម្រិតពាក់ព័ន្ធនឹងការស្វែងរកអង្គហេតុសំខាន់នៃបទល្មើសដែលត្រូវបានរាយការណ៍ ឬការចោទប្រកាន់ដែលត្រូវបានស្នើឡើង។ ជាទូទៅ ការរាយការណ៍នានាត្រូវបានធ្វើឡើង តែនៅពេលដែលមានធាតុផ្សំនៃបទល្មើសច្បាស់លាស់ និងបទល្មើសដែលគេយល់ច្បាស់ប៉ុណ្ណោះ ដូចជាការកេងប្រវ័ញ្ចផ្លូវភេទ។ ហេតុនេះ បើគ្មានការស៊ើបអង្កេតបែបបុរេសកម្មដើម្បីស្វែងរកវិសាលភាពពេញលេញនៃការប្រព្រឹត្តអំពើល្មើស រួមមានការស្រាវជ្រាវថាតើមានការនាំយកកុមារដែលជាកម្មវត្ថុនៃការកេងប្រវ័ញ្ចចេញដោយខុសច្បាប់ដែរឬទេនោះទេ កំណត់ហេតុលើការស្រាវជ្រាវមិនទំនងជាបញ្ជាក់អំពីអត្តិភាពនៃអំពើដែលនាំឱ្យមានការចោទប្រកាន់ពីបទល្មើសជួញដូរកុមារឡើយ។ ការរួមផ្សំនៃកត្តាទាំងនេះបានជះឥទ្ធិពលអវិជ្ជមានទៅលើលទ្ធភាពនៃការពិនិត្យអត្តិភាពនៃបទល្មើស និងការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងទៅលើការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ និងជនល្មើសទាំងអស់។ ផលប៉ះពាល់គួរឱ្យកត់សម្គាល់បំផុតនៃឧបសគ្គទាំងនេះ គឺទៅលើការស្វែងរក និងការផ្តន្ទាទោសអំពើល្មើសនានា ដែលពាក់ព័ន្ធនឹងគោលដៅទាំងឡាយណាក្រៅពីការកេងប្រវ័ញ្ចផ្លូវភេទ រួមមានការស្វែងរកប្រយោជន៍ និងសុំកូន។ ស្ទើរតែគ្រប់ករណីទាំងអស់ដែលបានឈានដល់ដំណាក់កាលជំនុំជម្រះ ជនល្មើសត្រូវបានផ្តន្ទាទោសពីបទល្មើសពាក់ព័ន្ធការបំពានខាងផ្លូវភេទ ពោលគឺមិនមែនបទល្មើសជួញដូរឡើយ ថ្វីបើបទល្មើសមួយចំនួនកំពុងកើតឡើងនៅកន្លែងថែទាំកុមារបែបលួចលាក់ ដែលមានការនាំយកកុមារចេញមិនស្របច្បាប់តាំងពីដំបូងក្តី។

ឧបសគ្គមួយចំនួននៅក្នុងប្រព័ន្ធកិច្ចការពារកុមារ និងការថែទាំជំនួសក៏ត្រូវបានរកឃើញផងដែរ។ ឧបសគ្គទាំងនោះរួមមាន ការអនុវត្តមិនមានសង្គតិភាពគ្មានូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារដែលមានចរិតលក្ខណៈ

ដើម្បីទប់ស្កាត់បទល្មើស ដូចជា ការដាក់ទោសនីតិបុគ្គលដែលដំណើរការកន្លែងថែទាំកុមារដោយលួចលាក់[4] និងភាពខុសគ្នាពាក់ព័ន្ធនឹងភាពហ្មត់ចត់ និងភាពទៀងទាត់នៃការធ្វើអធិការកិច្ចកន្លែងថែទាំកុមារ។ តាមរយៈការសិក្សាស្រាវជ្រាវ ក៏មានការកត់សម្គាល់ឃើញពីភាពខ្វះចន្លោះនានាក្នុងការអនុវត្តនីតិវិធីច្បាប់ ដែលគ្រប់គ្រងលើការទទួលយកកុមារចូលកន្លែងថែទាំកុមារ និងផលវិបាកនៃការទទួលយកកុមារចូលក្នុងកន្លែងថែទាំកុមារដោយមិនប្រក្រតី។ នៅពេលខ្លះ ឧបសគ្គទាំងនេះបង្កឡើងពីកត្តាខាងក្រៅមកលើអាជ្ញាធរដែលមានសមត្ថកិច្ចការពារកុមារ ដែលធ្វើឱ្យអ្នកទាំងនោះមិនអាចអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាទៅលើកន្លែងថែទាំកុមារជាក់លាក់មួយចំនួនបាន ដោយសារឧបសគ្គផ្នែកដែនសមត្ថកិច្ច ឬដោយសារវត្តមាននៃអ្នកឧបត្ថម្ភ (patron)។ ការអនុវត្តដោយគ្មានសង្គតិភាពគ្មាននូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួស និងក្របខណ្ឌតាមដានត្រួតពិនិត្យ ត្រូវបានរកឃើញថាបានធ្វើឱ្យមានការកាត់បន្ថយការការពារសុវត្ថិភាពសម្រាប់កុមារនៅតាមកន្លែងថែទាំ។ វាបានកាត់បន្ថយនូវលទ្ធភាពនៃការរកឃើញអំពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងអំពើជួញដូរដែលកើតមានឡើងនៅក្នុងមណ្ឌលកុមារកំព្រា និងលទ្ធភាពនៃការកសាងសំណុំរឿងទាំងនោះដើម្បីធ្វើការស៊ើបអង្កេត និងអន្តរាគមន៍។

ឧបសគ្គនានាក្នុងការពិនិត្យអត្ថិភាពនៃបទល្មើស ការរាយការណ៍ និងការផ្តន្ទាទោសក៏បានកើតចេញពីប្រតិបត្តិការផ្ទៃក្នុងរបស់កន្លែងថែទាំកុមារផងដែរ។ នៅក្នុងករណីជាច្រើន ឧបសគ្គទាំងនោះមានទំនាក់ទំនងជាមួយនឹងថាមវន្តអំណាចរវាងប្រធានកន្លែងថែទាំកុមារ បុគ្គលិក កុមារ និងគ្រួសាររបស់ពួកគេ ឬអ្នកឧបត្ថម្ភខាងក្រៅ។ ថាមវន្តអំណាចបូកផ្សំជាមួយនឹងបរិយាកាសបិទជិតនៅមណ្ឌលកុមារកំព្រារមែងតែងធ្វើឱ្យកុមារគ្មានសុវត្ថិភាពក្នុងការបង្ហាញអំពីការរំលោភបំពាន នៅពេលដែលអំពើនោះកំពុងកើតឡើង និងកើតឡើងស្របពេលដែលពួកគេកំពុងស្ថិតនៅក្រោមការគ្រប់គ្រង និងអំណាចរបស់ជនល្មើស។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការបង្ខិតបង្ខំ និងការគំរាមកំហែងគឺជាវិធីសាស្ត្រទូទៅ ដែលជនល្មើសប្រើប្រាស់ដើម្បីបំបិទមាត់កុមារ និងគ្រួសារ និងរារាំងដល់ការរាយការណ៍។ ជាលទ្ធផល ការបង្ហាញពីអត្ថិភាពនៃបទល្មើសដោយកុមារ ឬយុវជនរមែងតែងកើតឡើងបន្ទាប់ពីពួកគេ បានចាកចេញពីកន្លែងថែទាំកុមារហើយប៉ុណ្ណោះ។ ក៏មានការលើកឡើងថា ការដោះស្រាយក្រៅប្រព័ន្ធតុលាការក៏ជាឧបសគ្គមួយផងដែរ។ នៅពេលខ្លះ ការដោះស្រាយបែបនេះ បង្កើតបានជាលទ្ធផលដែលធ្វើឱ្យជនរងគ្រោះ និងសាក្សីផ្លាស់ប្តូរចិត្តនៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត ហើយក្នុងករណីដទៃទៀត មានការបង្កការរាំងស្ទះ និងការគេចវេសពីបណ្តឹងដែលត្រូវបានដាក់ជាមួយមន្ត្រីនគរបាលយុត្តិធម៌។ ថាមវន្តអំណាចដូចគ្នាទាំងនេះក៏ត្រូវបានគេកត់សម្គាល់ថាមានផលប៉ះពាល់ទៅលើការយល់ឃើញរបស់កុមារ និងគ្រួសាររបស់ពួកគេអំពីបទល្មើសផងដែរ និងបង្កឱ្យមានការកាត់បន្ថយការរាយការណ៍ និងការរាយការណ៍មិនគ្រប់ជ្រុងជ្រោយអំពីការប្រព្រឹត្តបទល្មើស។ បញ្ហានេះកើតឡើងដោយសារវប្បធម៌នៃការមានផ្នត់គំនិតដឹងគុណ និងភក្តីភាពចំពោះប្រធាន និងអ្នកថែទាំក្នុងមណ្ឌលកុមារកំព្រា ដែលដើរតួជាអ្នកជួយឧបត្ថម្ភ ឬអ្នកមានគុណនៅក្នុងជីវិតរបស់កុមារ ដោយបានផ្តល់ដល់ពួកគេនូវជម្រក អាហារ និងការអប់រំ។ ការណ៍នេះធ្វើឱ្យកុមារទំនងជាមានទំនោរគិតថាការកេងប្រវ័ញ្ច គឺជាការសមហេតុផល ដោយចាត់ទុកថាវាជាមធ្យោបាយដែលពួកគេបានសងគុណដល់ប្រធានមណ្ឌលកុមារកំព្រា (ករណីប្រធានមណ្ឌល គឺជាជនល្មើស)។ ដោយសារការមានភក្តីភាពចំពោះប្រធានមណ្ឌល ឬអ្នកជួយឧបត្ថម្ភ កុមារក៏មានអារម្មណ៍ថា ពួកគេមានកាតព្វកិច្ចនៅស្ងៀមផងដែរ។ បន្ថែមពីនេះ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា មណ្ឌលកុមារកំព្រា ដែលមានអ្នកជួយឧបត្ថម្ភពីខាងក្រៅ រមែងតែងរួចផុតពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឬក៏ទទួលបានការការពារពីផលវិបាកតាមផ្លូវច្បាប់ពីការប្រព្រឹត្តមិនស្របច្បាប់ ឬការប្រព្រឹត្តអំពើល្មើស។ បញ្ហានេះបង្កជាឧបសគ្គចំពោះការអនុវត្តប្រកបដោយសង្គតិភាពនូវក្របខណ្ឌច្បាប់ និងចំពោះសមត្ថភាពរបស់អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការធ្វើអន្តរាគមន៍នៅក្នុងប្រតិបត្តិការរបស់មណ្ឌលកុមារកំព្រាជាក់លាក់មួយចំនួន។

---

4 ច្បាប់បានកំណត់ថា ជាកន្លែងថែទាំកុមារដែលគ្មានការអនុញ្ញាត។

# អនុសាសន៍

## ការពង្រឹងការយល់ដឹង និងការបណ្តុះបណ្តាល

របកគំហើញនៃការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថាមានភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្ត ហើយក្នុងវិស័យខ្លះ ការយល់ដឹងនៅមានកម្រិតនៅឡើយអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងសូចនាករនានានៃបទល្មើសនេះ។ បញ្ហានេះបានបង្កឱ្យមានការមិនបានកត់សម្គាល់ ឬការបកស្រាយខុសអំពីសូចនាករនៃបទល្មើស និងការរាយការណ៍អំពីបទល្មើស ឬធាតុផ្សំនៃបទល្មើសជួញដូរមិនគ្រប់ជ្រុងជ្រោយ ហើយជនរងគ្រោះនៅតែគ្មានការកំណត់អត្តសញ្ញាណច្បាស់លាស់ និងបន្តស្ថិតក្នុងស្ថានភាពនៃការកេងប្រវ័ញ្ច និងហានិភ័យនានា។ របកគំហើញទាំងនេះបង្ហាញអំពីតម្រូវការក្នុងការពង្រឹងការយល់ដឹងជាទូទៅអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងសូចនាករនៃបទល្មើសនេះឱ្យបានទូលំទូលាយនៅក្នុងវិស័យកិច្ចការពារកុមារ ការអនុវត្តច្បាប់ វិស័យប្រឆាំងអំពើជួញដូរមនុស្ស និងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។ ដូចនេះ គប្បីអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលមានសមត្ថកិច្ចការពារកុមារ និងយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីពង្រឹងចំណេះដឹង និងបង្កើនអត្រានៃការស្វែងរក ការរាយការណ៍ ការស៊ើបអង្កេត ការផ្តន្ទាទោស និងការផ្តល់ដំណោះស្រាយសម្រាប់ជនរងគ្រោះ។ ក្នុងកម្រិតអប្បបរមា គប្បីមានការផ្តួចផ្តើមលើកកម្ពស់ការយល់ដឹងដែលផ្តោតគោលដៅលើ៖

- អាជ្ញាធរដែលមានសមត្ថកិច្ចការពារកុមារ រួមទាំងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការពិនិត្យអត្តិភាពនៃបទល្មើស និងការរាយការណ៍ នៅក្នុងបរិបទនៃការធ្វើអធិការកិច្ចកន្លែងថែទាំកុមារ ការរាយការណ៍ និងការឆ្លើយតបនឹងបញ្ហាកិច្ចការពារកុមារ និងនៅក្នុងការអនុវត្តមុខងារទប់ស្កាត់ការទទួលយកកុមារចូលក្នុងការថែទាំជំនួស។
- បុគ្គលិកសង្គមកិច្ច និងអ្នកគ្រប់គ្រងករណី រួមមានភ្នាក់ងារសង្គមកិច្ចរបស់មន្ទីរ ស.អ.យ និងបុគ្គលិកសង្គមកិច្ចរបស់អង្គការសង្គមស៊ីវិល ដើម្បីពង្រឹងការពិនិត្យអត្តិភាពនៃបទល្មើស ការរាយការណ៍ និងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅក្នុងបរិបទនៃការគ្រប់គ្រងករណីសម្រាប់សមាហរណកម្ម និងការគាំទ្របច្ចេកទេសសម្រាប់ការបិទ ឬការបង្វែរមណ្ឌលកុមារកំព្រា។
- មន្ត្រីអនុវត្តច្បាប់ រួមមាននគរបាលយុត្តិធម៌ និងអង្គភាពប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីពង្រឹងសមត្ថភាពក្នុងការពិនិត្យរបាយការណ៍ និងបណ្តឹង និងការបង្ហាញ ឬការប្រមូលភស្តុតាងសមស្របក្នុងអំឡុងពេលស៊ើបអង្កេត។ ការពង្រឹងចំណេះដឹងនៅក្នុងចំណោមមន្ត្រីអនុវត្តច្បាប់នឹងគាំទ្រដល់វិសាលភាពនៃការស៊ើបអង្កេតកាន់តែទូលំទូលាយ ដើម្បីជួយដល់ការរកឃើញធាតុផ្សំនានានៃអំពើជួញដូរ ក្រៅពីធាតុផ្សំដែលត្រូវបានរាយការណ៍។
- តុលាការ និងមន្ត្រីតុលាការ រួមមានក្រឡាបញ្ជី ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ ដើម្បីបង្កើនការយល់ដឹងទូទៅអំពីបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងចំណេះដឹងឯកទេសក្នុងការកំណត់បទល្មើសដែលមានចែងនៅក្នុងច្បាប់ TSE ទៅលើអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងធាតុផ្សំរបស់វា។
- អង្គការសង្គមស៊ីវិល រួមមានអង្គការទាំងឡាយដែលមានកម្មវត្ថុផ្តោតលើអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើកុមារ ជំនួយផ្នែកច្បាប់ និងសិទ្ធិមនុស្ស។ អង្គការទាំងនេះរមែងតែងផ្តល់ការគាំទ្រដល់មន្ត្រីអនុវត្តច្បាប់ ឬជនរងគ្រោះនៅតាមដំណាក់កាលនានានៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

## ការពង្រឹងការអនុវត្តយន្តការដែលមានស្រាប់

ការសិក្សាស្រាវជ្រាវនេះ បានគូសបញ្ជាក់នូវសារសំខាន់យ៉ាងច្បាស់ក្នុងការពង្រឹងការអនុវត្តច្បាប់ដែលមានចរិតលក្ខណៈដើម្បីទប់ស្កាត់បទល្មើស គោលនយោបាយ និងយន្តការតាមដានត្រួតពិនិត្យការថែទាំជំនួស ដើម្បីកាត់បន្ថយអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងពង្រឹងការពិនិត្យអត្តិភាពនៃបទល្មើស និងការធ្វើកិច្ចអន្តរាគមន៍តាំងពីដំបូង។ ច្បាប់ជាធរមានដែលបញ្ញត្តអំពីទណ្ឌកម្មចំពោះប្រតិបត្តិការកន្លែងថែទាំកុមារដោយគ្មានការអនុញ្ញាត (ដោយលួចលាក់) ការនាំយកកុមារចេញដោយមិនស្របច្បាប់ និងការញុះញង់ឱ្យមានការបោះបង់កុមារចាំបាច់ត្រូវតែអនុវត្តជាប្រចាំ។ ការធ្វើនេះ គឺជាការចាំបាច់ដើម្បីកាត់បន្ថយប្រតិបត្តិការមណ្ឌលកុមារកំព្រាដោយគ្មានការអនុញ្ញាត ដែលជាហេតុអំពើជួញដូរកុមារ និងការកេងប្រវ័ញ្ចកើតឡើងជាញឹកញាប់បំផុត និងដើម្បីរារាំងសកម្មភាពជនល្មើស។ ការអនុវត្តកាន់តែតឹងរ៉ឹងនូវច្បាប់ដែលមានចរិតលក្ខណៈដើម្បីទប់ស្កាត់បទល្មើសនឹងចូលរួមដោះស្រាយបញ្ហានៃការយល់ឃើញថាវាជារឿងធម្មតាក្នុងការប្រតិបត្តិកន្លែងថែទាំកុមារមិនស្របច្បាប់ និងការនាំយកចេញដោយមិនស្របច្បាប់ ដែលតាមរយៈរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា បញ្ហានេះធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យអត្តិភាពនៃបទល្មើស។

ការសិក្សាស្រាវជ្រាវនេះ ក៏បានបង្ហាញពីសារសំខាន់នៃការពង្រឹងការធ្វើអធិការកិច្ចកន្លែងថែទាំកុមារ និងប្រព័ន្ធតាមដានត្រួតពិនិត្យផងដែរ។ មន្ត្រីអធិការកិច្ច ដែលមានសមត្ថកិច្ចចូលទៅត្រួតពិនិត្យប្រតិបត្តិការនៃកន្លែងថែទាំកុមារមានឱកាសច្រើនជាងគេបំផុតក្នុងការរកឃើញនូវសូចនាករនានានៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងរាយការណ៍អំពីអំពើជួញដូរទាំងនោះ។ ទោះបីជាយ៉ាងណាក្តី កិច្ចការនេះត្រូវការការធ្វើអធិការកិច្ចស៊ីជម្រៅ និងហ្មត់ចត់ប្រកបដោយសង្គតិភាព និងការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាក្នុងការធ្វើការងារប្រកបដោយភាពសុចរិត និងតម្លាភាព។ ភាពមិនប្រក្រតីនានាដែលត្រូវរកឃើញនៅក្នុងដំណើរការអធិការកិច្ច គប្បីត្រូវបានលើកយកមកដោះស្រាយជាប្រចាំ ដោយផ្អែកលើវិធានការកែតម្រូវដែលត្រូវបានកំណត់ជាមុន។ ការពិចារណានានាត្រូវផ្តល់ចំពោះការតាមដានត្រួតពិនិត្យលើការធ្វើអធិការកិច្ច និងការគ្រប់គ្រងមន្ត្រីអធិការកិច្ច ដើម្បីទប់ស្កាត់ការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួន រវាងមន្ត្រីអធិការកិច្ច និងកន្លែងថែទាំកុមារ និងអាកប្បកិរិយាស្វែងរកផលចំណេញ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការធ្វើអធិការកិច្ច ឬការអនុវត្តចំណាត់ការតាមដានបន្ត។

## កំណែទម្រង់ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងពិធីសារនានា

របកគំហើញនៃការសិក្សាស្រាវជ្រាវនេះបានកំណត់វិធីសាស្រ្តជាច្រើន ដើម្បីពង្រឹងក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធវិស័យប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ ដើម្បីប្រយុទ្ធប្រឆាំង និងពង្រឹងការផ្តន្ទាទោសអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។

1 ទីមួយ - វាជាការចាំបាច់សម្រាប់កម្ពុជាក្នុងការបោះជំហានទៅកាន់ការអនុម័តបទល្មើសពាក់ព័ន្ធនឹងការលួងលោម។ ការលួងលោមកុមារដែលមានអាយុក្រោមនីតិភាពនៃការរួមភេទ គប្បីត្រូវចាត់ទុកជាបទល្មើសជាក់លាក់មួយ។ ការផ្តន្ទាទោសក៏គប្បីកើតឡើងចំពោះការលួងលោមដែលប្រព្រឹត្តលើបុគ្គលដែលកុមារទុកចិត្ត (សមាជិកគ្រួសារ ឬអ្នកអាណាព្យាបាល) និងការលួងលោមកុមារអាយុក្រោម ១៨ឆ្នាំ ពីសំណាក់បុគ្គលដែលស្ថិតក្នុងតួនាទីមានឥទ្ធិពល ឬអំណាចលើកុមារ ឬទទួលបានការទុកចិត្តពីកុមារផងដែរ។ ប្រធាន និងបុគ្គលិកកន្លែងថែទាំកុមារគប្បីស្ថិតនៅក្នុងនិយមន័យនៃ "បុគ្គលដែលមានឥទ្ធិពល ឬអំណាចលើកុមារ ឬទទួលបានការទុកចិត្តពីកុមារ"។ ការអនុម័ត និងការយល់ដឹងអំពីបទល្មើសលួងលោមទំនងជានាំឱ្យមានឥទ្ធិពលជាវិជ្ជមានទៅលើការពិនិត្យអត្តិភាពនៃបទល្មើស និងការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ ការអនុម័តលើបទល្មើសលួងលោមនឹងធ្វើឱ្យសូចនាករមួយចំនួននៃអំពើជួញដូរកុមារក្នុង

មណ្ឌលកុមារកំព្រា ក្លាយជាបទល្មើសដាច់ដោយឡែក ដែលជាការពង្រឹងដល់ការអនុវត្តច្បាប់ និងមន្ត្រីមានសមត្ថកិច្ចក្នុងការស្វែងរកសូចនាករទាំងនោះ។ វានឹងពង្រឹងមូលដ្ឋានផ្លូវច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចការពារកុមារ ក្នុងការធ្វើកិច្ចអន្តរាគមន៍នៅក្នុងស្ថានភាពមួយដែលការរំលោភបំពានមិនទាន់ត្រូវបានរាយការណ៍នៅឡើយ និងបង្កើនឱកាសនៃការធ្វើកិច្ចអន្តរាគមន៍នៅមុនពេលការកេងប្រវ័ញ្ចផ្លូវភេទកើតឡើង។ ការធ្វើបែបនេះនឹងបង្កើនលទ្ធភាពនៃការផ្តន្ទាទោសជនល្មើស ដោយផ្អែកលើចេតនាក្នុងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលត្រូវបាននាំយកចេញដោយមិនស្របច្បាប់។ ការចែងច្បាស់លាស់អំពីអំពើលួងលោមទំនងជាពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ និងតុលាការក្នុងការបង្ហាញពីភាពខុសគ្នារវាងសូចនាករនៃការកេងប្រវ័ញ្ច ឬចេតនាក្នុងការកេងប្រវ័ញ្ច និង “ការផ្តល់ការថែទាំ” ដែលការសិក្សាស្រាវជ្រាវនេះបានកំណត់ថាជាឧបសគ្គចំពោះការបកស្រាយច្បាប់ និងការផ្តន្ទាទោស ។

2

ទីពីរ - គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប[5] គប្បីត្រូវធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ដើម្បីបញ្ចូលសូចនាករនានានៃទម្រង់ដែលលេចឡើងថ្មីៗនៃអំពើជួញដូរមនុស្ស រួមមានអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ ការរៀបចំជាគោលនយោបាយ ឬឯកសារតាមវិស័យអមជាមួយនឹងគោលការណ៍ណែនាំនេះនឹងជួយបំភ្លឺអំពីសូចនាករសំខាន់ៗមួយចំនួននៃអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងមធ្យោបាយចម្បងក្នុងការស្វែងរកបទល្មើស និងបកស្រាយច្បាប់។ សេចក្តីណែនាំគប្បីផ្តោតសំខាន់លើការបំភ្លឺអំពីការនាំយកចេញដោយមិនស្របច្បាប់ ត្បិតវាកើតឡើងរួមគ្នាជាមួយនឹងការនាំយកចេញ និងការទុកដាក់កុមារនៅក្នុងការកន្លែងថែទាំកុមារ។ ព័ត៌មានច្បាស់លាស់អំពីអំណាច និងសមត្ថកិច្ចដែលច្បាប់បានផ្តល់ឱ្យសម្រាប់ការនាំយកចេញ និងការទុកដាក់កុមារនៅកន្លែងថែទាំកុមារ ត្រូវរៀបចំឱ្យមាន និងផ្សព្វផ្សាយទៅដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅទូទាំងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ វិស័យកិច្ចការពារកុមារ និងវិស័យប្រឆាំងអំពើជួញដូរមនុស្ស។ ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពបែបនេះ នឹងដោះស្រាយឧបសគ្គមួយចំនួនក្នុងចំណោមឧបសគ្គនានាក្នុងការការកំណត់អត្ថិភាពនៃបទល្មើស និងការផ្តន្ទាទោសបទល្មើសជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា រួមទាំងការផ្តល់ចំណេះដឹងអំពីសូចនាករនានា និងការបកស្រាយសូចនាករទាំងនោះផ្អែកតាមច្បាប់។

3

ទីបី - គប្បីរៀបចំពិធីសារស៊ើបអង្កេត ដើម្បីជាមគ្គុទេសក៍សម្រាប់ការប្រមូលភស្តុតាងនៅគ្រប់ករណីទាំងអស់ ដែលមានការរាយការណ៍ ឬដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពានកុមារ ការកេងប្រវ័ញ្ចកុមារ និងសុំកូន ដែលមានទំនាក់ទំនងជាមួយនឹងកន្លែងថែទាំកុមារ។ ពិធីសារនេះគប្បី៖

(ក) ណែនាំមន្ត្រីទទួលបន្ទុកការស៊ើបអង្កេតក្នុងការពិនិត្យជាប្រចាំទៅលើនីត្យានុកូលភាពពាក់ព័ន្ធនឹងការនាំយកកុមារចេញពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល និងការទុកដាក់នៅក្នុងកន្លែងថែទាំកុមារ និងផ្តល់សេចក្តីណែនាំជាក់លាក់ ដើម្បីជាជំនួយដល់ការបកស្រាយអង្គហេតុដែលប្រមូលបាន។

(ខ) តម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរ ស្នើសុំជាប្រចាំនូវព័ត៌មានពាក់ព័ន្ធនឹងការធ្វើអធិការកិច្ច និងការចុះបញ្ជីអំពីកន្លែងថែទាំកុមារដែលជាកម្មវត្ថុនៃការចោទប្រកាន់ពីក្រសួង ស.អ.យ ឬមន្ទីរ ស.អ.យ នៅគ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងមណ្ឌលកុមារកំព្រា។ ការធ្វើបែបនេះនឹងជួយដល់មន្ត្រីទទួលបន្ទុកការស៊ើបអង្កេតឱ្យដឹងថា តើកន្លែងថែទាំកុមារនោះកំពុងប្រតិបត្តិការដោយស្របច្បាប់ និងអនុវត្តស្របតាមបទដ្ឋានអប្បបរមាដែរឬទេ ហើយថាតើមានកំណត់ត្រាអំពីហេតុការណ៍ ឬការរំលោភបំពានច្បាប់ ឬបទដ្ឋានអប្បបរមាដែរឬទេ។

---

5 គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ឆ្នាំ២០១៥។

(គ) ណែនាំមន្ត្រីទទួលបន្ទុកការស៊ើបអង្កេតឱ្យចាត់ទុកកុមារទាំងអស់ ដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារដែលជាកម្មវត្ថុនៃការចោទប្រកាន់ថាសុទ្ធតែមានលទ្ធភាពអាចជាជនរងគ្រោះ សម្រាប់គោលបំណងនៃការស៊ើបអង្កេត និងការកំណត់អត្តសញ្ញាណជនរងគ្រោះ។

ពិធីសារស៊ើបអង្កេត ដែលកំណត់ឱ្យមន្ត្រីទទួលបន្ទុកការស៊ើបអង្កេតពិនិត្យពីស្ថានភាពផ្លូវច្បាប់របស់កន្លែងថែទាំកុមារ និងនីត្យានុកូលភាពនៃការនាំយកចេញ និងការទុកដាក់កុមារក្នុងកន្លែងថែទាំនឹងពង្រឹងលទ្ធភាពនៃការស្វែងរកនូវធាតុផ្សំនៃការនាំយកចេញដោយមិនស្របច្បាប់ និងការបង្កើតការសង្ស័យអំពីអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ ការរៀបចំឱ្យមានពិធីសារនេះ រួមជាមួយនឹងការវាយតម្លៃជាស្វ័យប្រវត្តិទៅលើស្ថានភាពរបស់កុមារទាំងអស់នៅក្នុងកន្លែងថែទាំកុមារ និងការកើនឡើងនូវការយល់ដឹង និងការបណ្តុះបណ្តាល អាចចូលរួមពង្រឹងលទ្ធភាពនៃការចោទប្រកាន់ជនល្មើសពីបទល្មើសជួញដូរកុមារ ហើយក៏អាចនាំឱ្យមានការអត្តសញ្ញាណជនល្មើសទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងគ្រប់ដំណាក់កាលនៃអំពើជួញដូរ និងអត្តសញ្ញាណជនរងគ្រោះដទៃទៀត។

4

ជាចុងក្រោយ ការគ្រប់គ្រងលើទេសចរណ៍ធ្វើការងារស្ម័គ្រចិត្ត និងការប្រើប្រាស់អ្នកស្ម័គ្រចិត្ត គឺជាយុទ្ធសាស្ត្រគន្លឹះមួយក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងវិស័យទេសចរណ៍។ ការគ្រប់គ្រងទេសចរណ៍ធ្វើការងារស្ម័គ្រចិត្តគប្បីត្រូវអនុវត្ត ដើម្បីគ្រប់គ្រងលើការប្រើប្រាស់អ្នកស្ម័គ្រចិត្តនៅគ្រប់ទីកន្លែងទាំងអស់ ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយកុមារ។ ការហាមឃាត់ជាក់លាក់លើទេសចរណ៍តាមមណ្ឌលកុមារកំព្រា ទេសចរណ៍ធ្វើការងារស្ម័គ្រចិត្ត និងការប្រើប្រាស់អ្នកស្ម័គ្រចិត្តគ្មានជំនាញនៅក្នុងកន្លែងថែទាំកុមារ គប្បីត្រូវបញ្ចូលក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសចរណ៍ធ្វើការងារស្ម័គ្រចិត្ត និងក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ គប្បីមានការចែងអំពីទណ្ឌកម្មចំពោះការរំលោភបំពានលើលិខិតបទដ្ឋានគតិយុត្តទាំងនេះ និងផ្តោតលើការដាក់ទោសនីតិបុគ្គល ដែលសម្របសម្រួល និង/ឬទទួលបានផលចំណេញពីទេសចរណ៍តាមមណ្ឌលកុមារកំព្រា និងទេសចរណ៍ធ្វើការងារស្ម័គ្រចិត្ត (ឧទាហរណ៍៖ ក្រុមហ៊ុនប្រកបអាជីវកម្មបញ្ជូនអ្នកស្ម័គ្រចិត្ត ឬអង្គការទទួលអ្នកស្ម័គ្រចិត្ត រួមមានជាអាទិ៍ កន្លែងថែទាំកុមារ ក្រុមហ៊ុនគ្រប់គ្រងនៅតំបន់គោលដៅ និងអ្នកផ្តល់សេវាទេសចរណ៍/ទេសចរណ៍ធ្វើការងារស្ម័គ្រចិត្តក្នុងស្រុក)។

ការហាមឃាត់ទេសចរណ៍ធ្វើការងារស្ម័គ្រចិត្តនៅមណ្ឌលកុមារកំព្រា នឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រាតាមរយៈវិធីជាច្រើន។ ការគ្រប់គ្រងលើការសម្របសម្រួលដល់ទេសចរណ៍ធ្វើការងារស្ម័គ្រចិត្តក្នុងមណ្ឌលកុមារកំព្រាដោយមិនស្របច្បាប់នឹងកាត់បន្ថយការជំរុញឱ្យមានអំពើជួញដូរកុមារចូលក្នុងកន្លែងថែទាំកុមារ ក្នុងគោលដៅស្វែងរកប្រយោជន៍ ដែលបង្កើតជាសមិទ្ធិផលនៃការទប់ស្កាត់អំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។ នេះធ្វើឱ្យសូចនាករនៃអំពើជួញដូរក្នុងទម្រង់ជាមណ្ឌលកុមារកំព្រា ជាពិសេស អំពើជួញដូរទាំងឡាយដែលមានគោលដៅស្វែងរកប្រយោជន៍ មានភាពច្បាស់លាស់ ដែលធ្វើឱ្យមានភាពងាយស្រួលដល់ភាគីពាក់ព័ន្ធក្នុងការអនុវត្តច្បាប់។ ដំណើរការច្បាស់លាស់នៃការរំលេចនូវអត្ថន័យនៃ "ការស្វែងរកប្រយោជន៍" នឹងជួយដល់ការស្វែងរក និងប្រមូលភស្តុតាង និងការចោទប្រកាន់ពីបទការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅស្វែងរកប្រយោជន៍ ត្រូវបានធ្វើឡើងនៅក្នុងករណីទាំងនេះ។ កត្តាទាំងនេះរួមបញ្ចូលគ្នាអាចពង្រឹងលទ្ធភាពនៃការផ្តន្ទាទោសជនល្មើស ដែលជួញដូរកុមារចូលក្នុងកន្លែងថែទាំកុមារ ក្នុងគោលគោលដៅស្វែងរកប្រយោជន៍ រួមទាំងបុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងការជ្រើសរើសកុមារពីគ្រួសាររបស់ពួកគេ។

ដើម្បីអានរបកគំហើញទាំងស្រុងនៃការសិក្សាស្រាវជ្រាវនេះ សូមមើលរបាយការណ៍ស្តីពីការអនុវត្តក្របខណ្ឌច្បាប់ចំពោះអំពើជួញដូរកុមារក្នុងមណ្ឌលកុមារកំព្រា។